ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១០៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលមាត្រា៦ មាត្រា៣១ មាត្រា៣២ មាត្រា៣៣ និងមាត្រា ៣៤ និងបំពេញបន្ថែមមាត្រា ៣៤ ថ្មីស្ទួន និង មាត្រា ៣៩ ស្ទួន នៃអនុក្រឹត្យ ២៧៤ អនក្រ.បក ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការ តែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១០២/០០១ ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ២០០២ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីក្រមការការបរទេស
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន

- បានឃើញអនុក្រឹត្យលេខ ៣២ អនក្រ.បក ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៩៦ ស្តីពីការចាត់តាំងនិងការប្រព្រឹត្តទៅនៃប្រព័ន្ធសម្របសម្រួលផ្ទៃក្នុង
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ២៧៤ អនក្រ.បក ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

## សម្រេច

**មាត្រាមួយ.-**

មាត្រា៦ នៃអនុក្រឹត្យលេខ ២៧៤ អនក្រ.បក ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ត្រូវបានកែសម្រួល និង បំពេញបន្ថែម ដូចតទៅ ៖

- កែសម្រួល ត្រេទី ៩ ចំណុច ក ទៅជា "វិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិ"
- កែសម្រួល ត្រេ ទី១០ ចំណុច ក ទៅជា "នាយកដ្ឋានព័ត៌មាន"
- បំពេញបន្ថែម ត្រេទី ១៣ ចំណុច ក នូវ "នាយកដ្ឋានព័ត៌មានវិទ្យា" ។
- បំពេញបន្ថែម ចំណុច គ នូវ "ក្រុមស្រាវជ្រាវ វិភាគ និងព្យាករណ៍" ។

**មាត្រាពីរ.-**

មាត្រា៣១ មាត្រា៣២ និងមាត្រា៣៣នៃជំពូកទី១១ ស្តីពីវិទ្យាស្ថានជាតិទំនាក់ទំនងការទូតនិងសិក្សាអន្តរជាតិ និងមាត្រា៣៤នៃជំពូកទី១២ស្តីពីនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និង ពត៌មាននៃអនុក្រឹត្យលេខ ២៧៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ត្រូវបានកែសម្រួល ចំណែកឯ មាត្រា៣៤ថ្មីស្ទួន មាត្រា៣៩ ស្ទួន ត្រូវបានបំពេញបន្ថែមទៅក្នុងអនុក្រឹត្យលេខ ២៧៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ដូចតទៅ ៖

## ជំពូកទី១១ ថ្មី
## វិទ្យាស្ថានជាតិការទូត និង ទំនាក់ទំនងអន្តរជាតិ

**មាត្រា៣១ ថ្មី.-**

វិទ្យាស្ថានជាតិការទូតនិងទំនាក់ទំនងអន្តរជាតិ បំពេញមុខងារជាសេនាធិការឱ្យក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ លើការងារបណ្តុះបណ្តាល និងស្រាវជ្រាវលើវិស័យការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ។

វិទ្យាស្ថានជាតិការទូតនិងទំនាក់ទំនងអន្តរជាតិ ត្រូវដឹកនាំដោយប្រធានមួយរូប អមដោយអនុប្រធានមួយចំនួន។ វិទ្យាស្ថាន អាចមានប្រធានកិត្តិយស ទីប្រឹក្សា និង អ្នកពិគ្រោះយោបល់ជាតិ និង បរទេស សម្រាប់ជួយដល់

ដំណើរការរបស់វិទ្យាស្ថាន ។ ប្រធានកិត្តិយស ទីប្រឹក្សា និង អ្នកពិគ្រោះយោបល់ជាតិ និងបរទេស ត្រូវតែងតាំង ដោយព្រះរាជក្រឹត្យ ឬ អនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

**មាត្រា៣២ ថ្មី.-**

វិទ្យាស្ថានជាតិការទូតនិងទំនាក់ទំនងអន្តរជាតិ មានភារកិច្ច ដូចតទៅៈ

- រៀបចំកម្មវិធីបណ្តុះបណ្តាល និង ស្រាវជ្រាវលើវិស័យការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- រៀបចំការជ្រើសរើសនិងការបណ្តុះបណ្តាលដល់មន្ត្រីរាជការដែលកំពុងបំពេញការងារនៅតាមក្រសួងស្ថាប័ននានា តាមរយៈវគ្គសុក្រឹតការ និងវគ្គបណ្តុះបណ្តាលជំនាញពាក់ព័ន្ធនឹងវិស័យការទូតនិងទំនាក់ទំនងអន្តរជាតិ
- ចូលរួមចំណែករៀបចំឱ្យមានការប្រឡងវាស់កម្រិតសមត្ថភាពជំនាញការទូតនិងទំនាក់ទំនងអន្តរជាតិ
- ចូលរួមចំណែកសិក្សាស្រាវជ្រាវ វាយតម្លៃស្ថានការណ៍ជាតិ និងពិភពលោក វិភាគយុទ្ធសាស្ត្រ និងផ្តល់យោបល់ក្នុងការរៀបចំគោលនយោបាយការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- រៀបចំកម្មវិធីបាឋកថា វេទិកាពិភាក្សា សិក្ខាសាលាជាតិតំបន់ និងអន្តរជាតិ និងព្រឹត្តិការណ៍នានាពាក់ព័ន្ធនឹងកិច្ចការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- សហការជាមួយស្ថាប័នជាតិ និងអន្តរជាតិនានា គ្រឹះស្ថានបណ្តុះបណ្តាលជាតិនិងអន្តរជាតិ ព្រមទាំងជាមួយដៃគូអភិវឌ្ឍន៍ក្នុងវិស័យឯកជន និងវិស័យសាធារណៈ ដើម្បីអភិវឌ្ឍសមត្ថភាពធនធានមនុស្ស និងស្ថាប័នក្នុងជំនាញការទូត និងទំនាក់ទំនងអន្តរជាតិ
- បណ្តុះបណ្តាលកម្មសិក្សាការី និងមន្ត្រីបរទេសតាមរយៈកិច្ចសហប្រតិបត្តិការអន្តរជាតិ
- រៀបចំ ចងក្រង និងបោះពុម្ពផ្សាយលើវិស័យការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បណ្តុះបណ្តាលជំនាញអ្នកបកប្រែភាសាបរទេស សម្រាប់បម្រើឱ្យវិស័យការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ។

**មាត្រា៣៣ ថ្មី.-**

វិទ្យាស្ថានជាតិការទូតនិងទំនាក់ទំនងអន្តរជាតិ មាននាយកដ្ឋានក្រោមឱវាទចំនួន ៥ (ប្រាំ) ដូចខាងក្រោមៈ

- នាយកដ្ឋានកិច្ចការទូទៅ ៖ បំពេញមុខងារសម្របសម្រួលកិច្ចការរដ្ឋបាល បុគ្គលិក ហិរញ្ញវត្ថុ ព័ត៌មានវិទ្យា និងធនធានឯកសាររបស់វិទ្យាស្ថាន។
- នាយកដ្ឋានបណ្តុះបណ្តាលៈ បំពេញមុខងារសម្របសម្រួលកិច្ចការបណ្តុះបណ្តាលដំបូង បណ្តុះបណ្តាលបន្ត និងជំនាញផ្សេងៗ លើវិស័យការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។
- នាយកដ្ឋានស្រាវជ្រាវ និង វិភាគយុទ្ធសាស្ត្រ ៖ បំពេញមុខងារសម្របសម្រួលកិច្ចការស្រាវជ្រាវ វិភាគយុទ្ធសាស្ត្រ សម្រាប់កិច្ចការបណ្តុះបណ្តាល និង បោះពុម្ពផ្សាយ ។
- នាយកដ្ឋានទំនាក់ទំនងសាធារណៈ ៖ បំពេញមុខងារសម្របសម្រួលកិច្ចការទំនាក់ទំនងជាមួយក្រសួងស្ថាប័នរដ្ឋ អង្គការជាតិ អង្គការអន្តរជាតិនិងដៃគូអភិវឌ្ឍន៍នានា និងសាធារណៈមតិជាតិនិងអន្តរជាតិ ។
- នាយកដ្ឋានភាសាបរទេស ៖ បំពេញមុខងារសម្របសម្រួលកិច្ចការបណ្តុះបណ្តាលមុខវិជ្ជាភាសាបរទេស កិច្ចការបណ្តុះបណ្តាលជំនាញអ្នកបកប្រែភាសាបរទេស និងកិច្ចការផ្តល់សេវាបកប្រែរបស់វិទ្យាស្ថាន។

ការរៀបចំ និងការប្រព្រឹត្តទៅនៃវិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ។

## ជំពូកទី១២ ថ្មី
## នាយកដ្ឋានព័ត៌មាន

**មាត្រា៣៤ ថ្មី.-**

នាយកដ្ឋានព័ត៌មាន ជាសេនាធិការឱ្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ លើការងារនាំពាក្យ ផ្សព្វផ្សាយព័ត៌មាន និងគ្រប់គ្រងឯកសារ។

## ជំពូកទី១២ ថ្មី ស្ទួន
## នាយកដ្ឋានព័ត៌មានវិទ្យា

**មាត្រា៣៤ ថ្មី ស្ទួន.-**

នាយកដ្ឋាន ព័ត៌មានវិទ្យា បំពេញមុខងារជាសេនាធិការឱ្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ លើការងារ ព័ត៌មានវិទ្យា និងគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍ ។

## ជំពូកទី១៦ ស្ទួន
## ក្រុមស្រាវជ្រាវ វិភាគ និង ព្យាករណ៍

**មាត្រា៣៩ ស្ទួន.-**

"ក្រុមស្រាវជ្រាវ វិភាគ និង ព្យាករណ៍" ត្រូវបានបង្កើត និង ត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក ។

**មាត្រាបី.-**

អង្គការលេខរបស់ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ដែលត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យ ២៧៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ត្រូវបានកែសម្រួលដូចមានកំណត់នៅក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រាបួន.-**

បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រាប្រាំ.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៩ ខែ មិថុនា ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ**

**ប្រាក់ សុខុន**

**កន្លែងទទួល៖**

-ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ